# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ ៨៨៦.កយ.រប-២០០៦

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោក លោកស្រី ប្រធានតុលាការខេត្ត ក្រុង**

**លោក លោកស្រី ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

***<u>កម្មវត្ថុ</u>:*** ស្តីពីការអនុវត្តរូបមន្តតុលាការព្រហ្មទណ្ឌ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោក-លោកស្រីជ្រាបថា កន្លងមកនៅតាមបណ្តុតុលាការអយ្យការខេត្ត-ក្រុង បានជួបការលំបាកក្នុងការអនុវត្តលើរូបមន្តចាស់ ដែលពុំបានឆ្លើយតបទៅនឹងតម្រូវការអនុវត្តជាក់ស្តែងក្នុងពេលបច្ចុប្បន្ននេះនៅឡើយ ។

ដើម្បីជាមូលដ្ឋានដល់ការដោះស្រាយនូវរាល់ការលំបាកទាំងនោះ ក្រសួងយុត្តិធម៌បានសហការជាមួយគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (CCAP) របស់ប្រទេសអូស្ត្រាលី ដែលធ្លាប់បានជួយធ្វើរូបមន្តចាស់នោះបានរៀបចំធ្វើការកែសម្រួល និងរៀបរៀងបង្កើតថ្មីនូវរូបមន្តមួយចំនួន ធ្វើយ៉ាងណាដើម្បីជួយបង្កលក្ខណៈងាយស្រួលឱ្យតុលាការ និងអយ្យការខេត្ត-ក្រុង អនុវត្តស្របតាមស្ថានភាពបច្ចុប្បន្នប្រកបដោយប្រសិទ្ធភាពខ្ពស់ក្រសួងសូមធ្វើការចែកជូននូវគំរូរូបមន្តទាំងនេះ ដូចមាននៅក្នុងសៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ ឆ្នាំ២០០៦ ដល់គ្រប់តុលាការ និងអយ្យការខេត្ត-ក្រុងទាំងអស់ដើម្បីប្រើប្រាស់ ។

ក្រសួងយុត្តិធម៌សង្ឃឹម និងជឿជាក់ថា លោក-លោកស្រី ប្រធានតុលាការ ព្រះរាជអាជ្ញាអមតុលាការខេត្តក្រុង នឹងខិតខំដោយឈរលើស្មារតីខ្ពស់ យកចិត្តទុកដាក់អនុវត្ត និងផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទទាំងអស់ឱ្យអនុវត្តនូវរូបមន្តទាំងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-តុលាការកំពូល និងមហាអយ្យការ

-សាលាឧទ្ធរណ៍ និងមហាអយ្យការ

-ដើម្បីជូនជ្រាប

-ឯកសារ - កាលប្បវត្តិ